ផេនីកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រែប្រួលវិជ្ជមាន
Working Together for Positive Change

# ទស្សនៈរបស់អង្គការសង្គមស៊ីវិល អំពីការរួមចំណែករបស់ប្រទេសកម្ពុជា ក្នុងការអនុវត្តន៍អនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDCs)

យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមទទួលស្គាល់ នូវសារៈសំខាន់នៃការរួមចំណែករបស់ប្រទេសកម្ពុជា (INDCs) ក្នុងដំណើរការចរចារក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដោយមានលក្ខណៈស្របទៅនឹងដំណើរការរៀបចំ INDCs ក្រោមការសម្របសម្រួលរបស់ក្រសួងបរិស្ថាន យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមចូលរួមចំណែកនូវទស្សនៈទូទៅមួយចំនួនស្តីពីដំណើរការរៀបចំ និងខ្លឹមសារនៃ INDCs របស់កម្ពុជា ដែលនឹងត្រូវបានដាក់ជូនលេខាធិការដ្ឋាននៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងខែ ធ្នូ ឆ្នាំ ២០១៥ ខាងមុខនេះ។

## ដំណើរការរៀបចំ INDCs៖

- ដើម្បីឲ្យមានការទទួលស្គាល់ជាលក្ខណៈជាតិ និងគ្រប់ជ្រុងជ្រោយល្អ ឯកសារ INDCs របស់ប្រទេសកម្ពុជា គួរមានការពិគ្រោះយោបល់ ការឆ្លុះបញ្ចាំងពីទស្សនៈ និងការចូលរួមរបស់ពីពហុភាគីពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិល និង ផ្នែកឯកជន និងផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភាជាតិ។
- យើងជាអង្គការសង្គមស៊ីវិលសូមគាំទ្រវាល់គោលការណ៍ណែនាំដ៏សមស្របមួយដើម្បីរៀបចំ INDCs ដោយស្ថាប័នឯកទេសបានតាក់តែងឡើង។
- ទោះបីជាវិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ វាមិនមែនជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជាក្តី ក៏យើងជឿថា ការអនុវត្តទាំងវិធានការកាត់បន្ថយការបំភាយ និងវិធានការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាមធ្យោបាយដ៏សមស្របមួយ ដើម្បីឆ្លើយតបទៅនឹងបញ្ហាការប្រែប្រួលអាកាសធាតុនៅថ្នាក់សហគមន៍ ហើយវាក៏ជាសារមួយបង្ហាញថា ទោះបីប្រទេសកម្ពុជា គឺជាប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយតែនេះគឺជាការចូលរួមចំណែករបស់ប្រទេសកម្ពុជា ក្នុងការប្តេជ្ញារួមគ្នាជាសកលចំពោះការកាត់បន្ថយការបញ្ចេញសារធាតុកាបោនរបស់ខ្លួន។ វាក៏ជាប្រការសំខាន់ផងដែរ ដែលគួរស្វែងរកយុទ្ធសាស្រ្តដែលជាប្រយោជន៍សម្រាប់ ទាំងវិធានការបន្សុំា និងការកាត់បន្ថយការបំភាយ ដែលអាចស្រូបយកនូវមូលនិធិអាកាសធាតុ ដោយសារ INDCs គឺជាមូលដ្ឋានគ្រឹះផ្លូវការមួយ ដែលតម្រូវឲ្យប្រទេសផ្តល់ជំនួយធ្វើការការសន្យាផ្តល់ជំនួយនាពេលអនាគតដ៏ខ្លី។
- ដំណើរការរៀបចំផែនការដ៏ពេញលេញមួយ តម្រូវឲ្យមានផែនការសកម្មភាពមួយរឹងមាំ ដោយផ្អែកលើភស្តុតាង រួមទាំង MRV[១]។ អាស្រ័យហេតុនេះ យើងខ្ញុំស្នើសុំឲ្យរៀបចំឯកសារ INDCs នេះ គួរផ្អែកលើមូលដ្ឋានវិទ្យាសាស្រ្ត ភ្ជាប់ជាមួយភស្តុតាងជាក់ស្តែង និងភាពប្រាកដនិយម ជាពិសេសលើការបន្សុំា និងហិរញ្ញប្បទាន។
- ការប្តេជ្ញារបស់ប្រទេសកម្ពុជាចំពោះការបន្សុំា និងការកាត់បន្ថយការបំភាយ គឺចាំបាច់ត្រូវមានលក្ខណៈសមាមាត្រ ផ្នែកហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យាពីប្រទេសអភិវឌ្ឍ។ ប៉ុន្តែការចូលរួមចំណែករបស់ថ្នាក់ជាតិចំពោះការប្តេជ្ញានេះ គួរគូសបញ្ជាក់នៅក្នុងឯកសារ INDCs នេះផងដែរ។
- គោលនយោបាយ និងផែនការជាតិនានាស្តីពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដូចជាផែនការជាតិស្តីពីការបន្សុំា (NAP) ផែនការយុទ្ធសាស្រ្តកម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ (CCCSP) ផែនការសកម្មភាពតាមវិស័យស្តីពីការប្រែប្រួលអាកាសធាតុ ផែនការមេស្តីពីកំណើនបៃតង និងផែនការសកម្មភាពសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR)[២] គឺជាឧទាហរណ៍ដ៏ល្អ ដែលត្រូវបញ្ជាក់នៅក្នុង INDCs។
- INDCs គួររៀបចំ ដោយផ្អែកលើមាគ៌ាអភិវឌ្ឍន៍ដែលបញ្ចេញសារធាតុកាបោនទាប ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេស ក៏ដូចជាការលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាផងដែរ ជាពិសេសជនក្រីក្រ និងអ្នកដែលងាយរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

[១] MRV = ដែលអាចវាស់បាន រាយការណ៍បាន និង ផ្ទៀងផ្ទាត់បាន
[២] DRR = ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

## ខ្លឹមសារនៃ INDCs៖

### ចំពោះការបន្សាំ ដោយអនុលោមតាមកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមស្នើឡើងនូវអាទិភាពដូចខាងក្រោម៖

- ផែនការ និងគោលនយោបាយលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរដាក់បញ្ចូល ការកសាងសមត្ថភាព ការផ្ទេរបច្ចេកវិទ្យា នវានុវត្តន៍កម្រិតមូលដ្ឋាន ប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រងធនធានទឹក និងការរកទីផ្សារ។ វាគឺជាប្រការសំខាន់ដែលត្រូវពង្រីកប្រព័ន្ធធារាសាស្ត្រ ជាពិសេសប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម និងបង្កើនសមត្ថភាពរក្សាទុកទឹកភ្លៀង ដើម្បីគាំទ្រកសិករតូចតាច និងវិស័យជលផល នៅពេលជួបគ្រោះរាំងស្ងួត និងទឹកជំនន់។ នៅក្នុងវិស័យរុក្ខាប្រមាញ់ យើងជឿថាយើងអាចអភិរក្សព្រៃឈើមានស្រាប់ និងដាំដើមឈើឡើងវិញថែមទៀត ដោយសហការជាមួយសហគមន៍ព្រៃឈើ ដែលបង្កើនជីវជាតិដី ទាក់ទាញទឹកភ្លៀងបានកាន់តែច្រើនរក្សាមីក្រូអាកាសធាតុ និងបង្កើនការរក្សាសំណើមនៅក្នុងដី។
- ការធ្វើពិពិធកម្មកាលានុវត្តភាពអាជីវកម្ម និងអន្តរាគមន៍ផ្អែកលើទីផ្សារ រួមទាំងការពង្រឹងគុណភាពនៃការវេចខ្ចប់ផលិតផលរបស់កសិករ និងការធានាតម្លៃទីផ្សារល្អ ដើម្បីបង្កើនប្រាក់ចំណូលរបស់សហគមន៍ងាយរងគ្រោះ។
- វិស័យសុខាភិបាល រួមមានហេដ្ឋារចនាសម្ព័ន្ធ WASH[៣] ធន់អាកាសធាតុបែបថ្មី ដូចជាអណ្តូងធន់នឹងទឹកជំនន់ បង្គន់សមស្របសំរាប់ប្រជាជនក្រីក្រ និងគ្រួសារងាយរងគ្រោះពីផលប៉ះពាល់នៃអាកាសធាតុ។
- ការទប់ទល់នឹងទឹកជំនន់ រួមមានការអភិរក្សបឹងនិងព្រែកធម្មជាតិ ការសម្អាតទឹកបែបធម្មជាតិ និង ការសាងសង់ប្រព័ន្ធលូទឹកកខ្វក់ផងដែរ។
- ការប្រើប្រាស់ដីធ្លី ប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម និងជីវភាពដោយជំរុញការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងការដាក់បញ្ចូលចំណេះដឹងក្នុងបរិបទសហគមន៍មូលដ្ឋាន។
- ទីលំនៅមានសុវត្ថិភាព ការរៀបចំផែនការនិងការគ្រប់គ្រងការប្រើប្រាស់ដីបានល្អ។
- រៀបចំ និងកែលម្អប្រព័ន្ធផ្តល់ព័ត៌មានជាមុន (EWS) និងព័ត៌មានឬការព្យាករណ៍អាកាសធាតុ ដែលផ្សារភ្ជាប់ជាមួយវិទ្យាសាស្ត្រ និងការស្រាវជ្រាវសហគមន៍ ហើយពង្រឹងការផ្សារភ្ជាប់រវាងប្រព័ន្ធផ្តល់ព័ត៌មានជាមុន និង ការព្យាករណ៍របស់រដ្ឋាភិបាលថ្នាក់ជាតិជាមួយសហគមន៍។

### ចំពោះយន្តការកាត់បន្ថយការបំភាយ យើងខ្ញុំសូមស្នើឡើងនូវការយកចិត្តទុកដាក់លើអាទិភាពដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ជាពិសេសនៅតាមរោងចក្រអគ្គិសនី និងនៅក្នុងទីលំនៅ វិស័យទេសចរណ៍ និងសេវាសណ្ឋាគារ និងជាពិសេសនៅតាមការិយាល័យសាធារណៈ (រដ្ឋាភិបាល)។
- ថាមពលកកើតឡើងវិញ (លើកកម្ពស់ការផ្សព្វផ្សាយ និងប្រើប្រាស់ជីវឧស្ម័ន ជីវម៉ាស ថាមពលព្រះអាទិត្យ និងវារីអគ្គិសនីខ្នាតតូច/មធ្យម) ដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងមនុស្សជាតិ។ ទំនប់វារីអគ្គិសនីខ្នាតធំ **មិនគួរ**ដាក់បញ្ចូលក្នុង INDCs ទេ។
- បន្តការយកចិត្តទុកដាក់លើប្រព័ន្ធថាមពលកកើតឡើងវិញ ដែលមានលក្ខណៈសមស្របតាមមូលដ្ឋានជាជាងពឹងលើប្រព័ន្ធបណ្តាញ ថាមពលថ្នាក់ជាតិ ដែលមានទ្រទ្រាយធំ។
- ប្រព័ន្ធដឹកជញ្ជូនសាធារណៈប្រកបដោយប្រសិទ្ធភាព និងមានការបំភាយកាបោនតិច (smart)។
- ការអភិរក្សព្រៃតាមរយៈយន្តការរ៉េដបូក។
- ការគ្រប់គ្រងសំណល់ (រឹង + រាវ)។
- កាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម ជីគីមី នៅក្នុងវិស័យកសិកម្ម និងកែលម្អការអនុវត្តកសិកម្ម ដែលបញ្ចេញកាបោនតិច។

ចំពោះការផ្តល់ហិរញ្ញប្បទាន គួរផ្តល់អាទិភាពទៅលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសលើការអនុវត្តផែនការជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAP) ប៉ុន្តែការកាត់បន្ថយការបំភាយ ដែលអាចជាប្រយោជន៍ដល់វិធានការណ៍ការបន្សាំ (ដូចជាជីវឧស្ម័ន និង រ៉េដបូក) ការកសាងភាពធន់ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព គួរគប្បីជំរុញ និងពង្រឹងបន្ថែម។ មធ្យោបាយ និងយន្តការផ្សេងៗទៀត ដូចជាការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា គឺជាកត្តាចាំបាច់។

---

[៣] WASH = ទឹក និង អានាម័យ

យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមអំពាវនាវឲ្យមានការរៀបចំផែនការដោយផ្អែកលើភស្តុតាងជាក់ស្តែង និងវិទ្យាសាស្ត្រ ពោលគឺផែនការកាត់បន្ថយការបំភាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និង ការលើកកំពស់ការយល់ដឹង រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ល។ ជាងនេះទៀត ប្រការសំខាន់គឺ ត្រូវផ្សារភ្ជាប់ការបន្សាំ និងកាត់បន្ថយការបំភាយទៅនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**សហការសម្របសម្រួលដោយ៖**

១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)
២. បណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCN)

**គាំទ្រដោយ៖**

១. អង្គការសេកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD)
២. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)
៣. អង្គការបង្កើនសមត្ថភាពសហគមន៍ដើម្បីអភិវឌ្ឍមន៍ (CCD-ខេត្តក្រចេះ)
៤. អង្គការលើកកម្ពស់ធនធានសហគមន៍ដើម្បីអភិវឌ្ឍន៍ (CRID)
៥. អង្គការ DanChurchAid/ChristianAid (DCA/CA)
៦. អង្គការ Forum Syd
៧. សមាគមកសិករខ្មែរ (KFA)
៨. អង្គការ Live & Learn Environmental Education Cambodia
៩. អង្គការភូមិខ្ញុំ (MVi)
១០. អង្គការអ្នកអភិវឌ្ឍសហគមន៍ (NAS)
១១. សមាគមចម្រើនជាតិ (NAPA)
១២. អង្គការនាគព័ន្ធដើម្បីអភិវឌ្ឍន៍ (NoD)
១៣. អង្គការគោលដៅយើង (OOO)
១៤. អង្គការអុកស្វាម (Oxfam)
១៥. អង្គការជំនួយអភិវឌ្ឍន៍ និង សន្តិភាព (PDAO)
១៦. អង្គការទឹកដីសុវណ្ណភូមិ (TDSP)
១៧. អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ (WOMEN)
១៨. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

## ទំនាក់ទំនង

**១. បណ្ឌិត តឹក វណ្ណារ៉ា**
តួនាទី: នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGOF) / សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលស្តីពីបរិស្ថាន និង ការប្រែប្រួលអាកាសធាតុ (NECA)
ទូរស័ព្ទ: (+៨៥៥)២៣ ២១៤ ៤២៩ / (+៨៥៥)១២ ៧៩៣ ៩៨៩
អ៊ីម៉ែល: vannara@ngoforum.org.kh

**២.លោក ទេព ប៊ុននី**
តួនាទី: ប្រធានក្រុមប្រឹក្សាភិបាលបណ្តាញស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា(CCCN)
ទូរស័ព្ទ: (+៨៥៥)១២ ៩០០ ៦០៤
អ៊ីម៉ែល: secretariat@cccn.org.kh

**៣. លោក ណុប ប៉ូលីន**
តួនាទី៖ បុគ្គលិកអង្គការ DCA/CA
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១៦ ២៦១/(+៨៥៥)៩២ ២២២ ៨១១
អ៊ីម៉ែល៖ nopo@dca.dk